# សុន្ទរកថាគន្លឹះ
# របស់ អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន
# ឧបនាយករដ្ឋមន្ត្រី, រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ,
# ថ្លែងក្នុង
# វេទិកាពន្ធដារកម្ពុជា

*រាជធានីភ្នំពេញ, ថ្ងៃ ព្រហស្បតិ៍ ៣ រោច, ខែ មាឃ, ឆ្នាំម្សាញ់, សប្តស័ក, ព.ស. ២៥៦៩*
*ត្រូវនឹងថ្ងៃទី ៥ ខែ កុម្ភៈ គ.ស. ២០២៦, ទីស្នាក់ការកណ្តាល នៃអគ្គនាយកដ្ឋានពន្ធដារ*

*****+*****

- ឯកឧត្តម, លោកជំទាវ, សមាជិក-សមាជិកា នៃរាជរដ្ឋាភិបាល;
- ឯកឧត្តម **គង់ វិបុល**, រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និង ជាប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ;
- អ្នកឧកញ៉ា **គិត ម៉េង**, ប្រធានសភាពាណិជ្ជកម្មកម្ពុជា;
- ឯកឧត្តម, លោកជំទាវ, ជាថ្នាក់ដឹកនាំក្រសួង-ស្ថាប័ន, តំណាងអង្គទូត និង តំណាងដៃគូអភិវឌ្ឍ;
- ឯកឧត្តម, លោកជំទាវ, ឧកញ៉ា, លោក, លោកស្រី, សមាជិក-សមាជិកា នៃអង្គពិធី, ជាទីមេត្រី!

ថ្ងៃនេះ, ខ្ញុំពិតជាមានសេចក្តីសោមនស្សរីករាយ ដោយបានមកចូលរួម ជាអធិបតីក្នុងពិធីបើក «**វេទិកាពន្ធដារកម្ពុជា**», ក្រោមប្រធានបទ៖ “**ការលើកកម្ពស់អនុលោមភាពសារពើពន្ធ សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចកម្ពុជា**», ដែលត្រូវបានសហការរៀបចំ ដោយអគ្គនាយដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង សភាពាណិជ្ជកម្មកម្ពុជា ។ ខ្ញុំសូមស្វាគមន៍យ៉ាងកក់ក្តៅចំពោះ ឯកឧត្តម, លោកជំទាវ, ឧកញ៉ា, លោក, លោកស្រី,

សមាជិក-សមាជិកា នៃអង្គពិធី ដែលបានឆ្លៀតពេលដ៏មានតម្លៃ អញ្ជើញចូលរួមក្នុងវេទិកា ដ៏មានសារៈសំខាន់នេះ ។

ខ្ញុំសូមសម្តែងនូវអំណរគុណ ជូនឯកឧត្តម **គង់ ទិបុល**, រដ្ឋមន្ត្រីប្រតិភូអមនាយក-រដ្ឋមន្ត្រី និង ជាប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ, ដែលបានថ្លែងសុន្ទរកថាស្វាគមន៍ ដ៏ក្បោះក្បាយ, និង សូមសម្តែងនូវការកោតសរសើរ និង ការវាយតម្លៃខ្ពស់ ចំពោះថ្នាក់ដឹកនាំ និង មន្ត្រីរាជការពន្ធដារគ្រប់កម្រិត នៃអគ្គនាយក-ដ្ឋានពន្ធដារ, ដែលបានផ្តួចផ្តើមរៀបចំវេទិកា ដ៏មានសារៈសំខាន់នេះឡើង ។ ជាមួយគ្នានេះ, ខ្ញុំក៏សូមសម្តែងនូវអំណរគុណ ជូនអ្នកឧកញ៉ា **គិត ម៉េង**, ប្រធានសភាពាណិជ្ជកម្មកម្ពុជា, ដែលបានថ្លែងសុន្ទរកថា ដ៏មានអត្ថន័យ, និង សូមកោតសរសើរវិស័យឯកជន ជារួម, ដែលបានចូលរួមសហការរៀបចំវេទិកានេះ និង តែងបានសហការស្អិតល្មួត ជាមួយអគ្គ-នាយកដ្ឋានពន្ធដារ នាពេលកន្លងទៅ, រហូតសម្រេចបានលទ្ធផលរួមគ្នាជាច្រើន គួរឲ្យកត់-សម្គាល់, ដូចត្រូវបានឆ្លុះបញ្ចាំង ក្នុងសុន្ទរកថាទាំងពីរ របស់ឯកឧត្តម **គង់ ទិបុល** និង របស់អ្នកឧកញ៉ា **គិត ម៉េង** នៅមុននេះបន្តិច ។ ច្បាស់ណាស់ថា ការរៀបចំនូវ **«វេទិកាពន្ធដារកម្ពុជា»** នេះ គឺជាការផ្តល់កាលានុវត្តភាពដ៏វិសេសមួយ ដើម្បីពង្រឹង និង ពង្រីកភាពជាដៃគូ ឲ្យកាន់តែប្រសើរឡើងថែមទៀត រវាងរដ្ឋបាលសារពើពន្ធ, វិស័យឯកជន, ក្រសួង-ស្ថាប័នពាក់ព័ន្ធ នៃរាជរដ្ឋាភិបាល, ដៃគូអភិវឌ្ឍ, ព្រមទាំង អង្គការ និង ស្ថាប័នអន្តរជាតិ, តាមរយៈការចូលរួមក្នុងកិច្ចសន្ទនា, ការផ្លាស់ប្តូរមតិយោបល់ និង បទពិសោធ, និង ការចែករំលែកនូវឧត្តមានុវត្ត លើប្រធានបទសំខាន់ៗ ដើម្បីជំរុញ និង លើកកម្ពស់អនុលោមភាពសារពើពន្ធ សំដៅធានានូវចីរភាពនៃកំណើនចំណូលជូនរដ្ឋ; បង្កើនជំនឿចិត្តរបស់វិស័យឯកជន មកលើយន្តការប្រមូលចំណូលរបស់រដ្ឋ; ព្រមទាំង រួមចំណែកពង្រឹងប្រព័ន្ធប្រមូលចំណូលពន្ធ ជូនរដ្ឋ ឲ្យកាន់តែមានប្រសិទ្ធភាព, ស័ក្តិសិទ្ធិភាព, តម្លាភាព, គណនេយ្យភាព, សមភាព និង សមធម៌ ។

## *ឯកឧត្តម, លោកជំទាវ, ឧកញ៉ា, លោក, លោកស្រី!*

ក្នុងរយៈពេលជិត ៣ ទសវត្សរ៍ ចុងក្រោយ, តាមរយៈការខិតខំឥតស្រាកស្រាន្ត និង ការកែទម្រង់មុតស្រួចឥតងាករេ លើគ្រប់វិស័យ របស់រាជរដ្ឋាភិបាល, ក្រោមការដឹកនាំដ៏ឈ្លាសវៃ ប្រកបដោយជវភាព និង ភាពប្រាកដនិយម របស់ **សម្តេចអគ្គមហាសេនាបតី-**

តេជោ **ហ៊ុន សែន**, អតីត **នាយករដ្ឋមន្ត្រី** និង បច្ចុប្បន្នជា **ប្រធានព្រឹទ្ធសភា**, និង ការបន្តវេនដឹកនាំ ដ៏ត្រឹមត្រូវ និង ប៉ិនប្រសប់ ប្រកបដោយចក្ខុវិស័យវែងឆ្ងាយ របស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**, **នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** សម្រាប់នីតិកាលទី ៧ នេះ នៃរដ្ឋសភា, កម្ពុជា បន្តសម្រេចបាននូវសមិទ្ធផលដ៏ធំធេងជាច្រើន និង បានផ្លាស់ប្តូរមុខមាត់ គួរជាទីមោទនៈ ដោយរក្សាបានយ៉ាងគត់មត់ នូវស្ថិរភាពនយោបាយ, សណ្តាប់ធ្នាប់សង្គម, សន្តិសុខ, សុវត្ថិភាព, ព្រមទាំង ធានាបានយ៉ាងរឹងមាំ នូវការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច និង ស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និង ហិរញ្ញវត្ថុសាធារណៈ ។ បន្ថែមលើនេះ, សេដ្ឋកិច្ចកម្ពុជា បានស្ទុះងើបឡើងវិញយ៉ាងរហ័ស និង បន្តឈរលើមាគ៌ានៃកំណើនដ៏រឹងមាំ បន្ទាប់ពីវិបត្តិនៃជំងឺកូវីដ-១៩ ជាសកល ទោះបីជាត្រូវបន្តពុះពារជម្នះ នូវបញ្ហាប្រឈម និង ភាពមិនប្រាកដប្រជាខ្ពស់ នៃស្ថានភាព តំបន់ និង សកល ដោយសារការបន្តប្រឈមមុខខាងភូមិសាស្ត្រនយោបាយកាន់តែស្រួចស្រាល់; ការបែកខ្ញែកនៃសេដ្ឋកិច្ចសកលដែលប៉ះពាល់ដល់កិច្ចសហប្រតិបត្តិការ និង ពាណិជ្ជកម្មអន្តរជាតិ; ការងើបមកវិញនៃនិន្នាការឯកតោភាគីនិយម; ភាពមិនច្បាស់លាស់នៃទស្សនវិស័យកំណើនសេដ្ឋកិច្ច នៃបណ្តាប្រទេស និង តំបន់ ជាដៃគូពាណិជ្ជកម្មសំខាន់ៗរបស់កម្ពុជា, ការប្រែប្រួលអាកាសធាតុ ។ល។

ក្នុងដំណាក់កាលថ្មីនៃការបន្តខិតខំអភិវឌ្ឍប្រទេស, ចាប់តាំងពីដើមនីតិកាលទី ៧ នេះ នៃរដ្ឋសភា, រាជរដ្ឋាភិបាល បានដាក់ចេញ និង កំពុង ជំរុញអនុវត្ត នូវ **យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី ១**, ទន្ទឹមគ្នានឹង **កម្មវិធីគោលនយោបាយអាទិភាព ចំនួន ៦** និង **វិធានការគន្លឹះ ចំនួន ៥**, សំដៅខិតខំជម្នះឲ្យបាន នូវបញ្ហាប្រឈម និង សម្របខ្លួនទៅនឹងការប្រែប្រួលនៃសភាពការណ៍ ដែលកើតឡើងជាបន្តបន្ទាប់ និង ដំណាលៗគ្នា ដោយតម្រូវឲ្យរាជរដ្ឋាភិបាល ចាត់វិធានការអន្តរាគមន៍ ឲ្យបានទាន់ពេល និង ចំទិសដៅ ប្រកបដោយប្រសិទ្ធភាព និង ស័ក្តិសិទ្ធិភាពខ្ពស់ ។ ជាលទ្ធផល, ទោះបីត្រូវប្រឈមនឹងភាពមិនប្រាកដប្រជាកាន់តែស្រួចស្រាល់ ក្នុងបរិការណ៍សកល ក៏ដូចជា ត្រូវប្រឈមនឹងការរំលោភលើអធិបតេយ្យជាតិ និង បូរណភាពទឹកដី យ៉ាងណាក្តី, ក៏សេដ្ឋកិច្ចកម្ពុជា ត្រូវបានរំពឹងថា អាចនឹងសម្រេចបានកំណើន ក្នុងរង្វង់ប្រមាណ ៥,២% ក្នុងឆ្នាំ ២០២៥ និង ប្រមាណ ៥% សម្រាប់ឆ្នាំ ២០២៦ នេះ ។

ទន្ទឹមនេះ, កិច្ចខិតខំឥតរាថយ និង ឆន្ទៈមោះមុត របស់រាជរដ្ឋាភិបាល, សំដៅកែលម្អបរិយាកាសសម្រាប់ធុរកិច្ច និង ការវិនិយោគ, បានជំរុញឲ្យការវិនិយោគផ្ទាល់ពីក្រៅប្រទេស

បន្តកើនខ្ពស់ គួរជាទីមោទនៈ ។ ជាក់ស្តែង, ផ្អែកតាមទិន្នន័យរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា, ការចុះបញ្ជីគម្រោងវិនិយោគពីបរទេស ក្នុងឆ្នាំ ២០២៥ កន្លងទៅ មានទំហំទុនសរុបប្រមាណ **១០ ប៊ីលានដុល្លារអាម៉េរិក**, មានកំណើន ៤៥% បើធៀបនឹងឆ្នាំ ២០២៤ ។ ជាមួយគ្នា, ក្នុងវិស័យពាណិជ្ជកម្មក្រៅប្រទេស, ការនាំចេញរបស់កម្ពុជា ក្នុងឆ្នាំ ២០២៥ ក៏បន្តរក្សាបាននូវចលនការកំណើនល្អ គួរឲ្យកត់សម្គាល់ ។ ជាក់ស្តែង, ការនាំចេញសរុប ក្នុងឆ្នាំ ២០២៥ បានកើនប្រមាណជាង ១៧%, បើធៀបនឹងឆ្នាំ ២០២៤ ។ មួយវិញទៀត, លំហូរទេសចរបរទេសមកកាន់កម្ពុជា, ពិសេស កញ្ចប់ទេសចរណ៍ទីផ្សារឆ្ងាយ, ក៏នៅដំណើរការជាធម្មតា និង មាននិន្នាការកើនផងដែរ តួយ៉ាងដូចជា ទេសចរ ពីអឺរ៉ុប, អូស្ត្រាលី និង ឥណ្ឌា ។

កំណើនសេដ្ឋកិច្ចដ៏រឹងមាំ ប្រកបដោយចីរភាព, ជាពិសេស ក្នុងរយៈពេលជាងពីរទសវត្សរ៍ មុនការមកដល់នៃវិបត្តិជំងឺកូវីដ-១៩ ជាសកល, ពិតជាបានរួមចំណែកយ៉ាងសំខាន់ ក្នុងការផ្តល់លទ្ធភាព ដល់រាជរដ្ឋាភិបាល, ម្យ៉ាង, ក្នុងការបង្កើនការវិនិយោគសាធារណៈលើហេដ្ឋារចនាសម្ព័ន្ធគ្រប់ប្រភេទ ដូចជា ផ្លូវថ្នល់, ស្ពាន, សាលារៀន, មន្ទីរពេទ្យ, ប្រព័ន្ធធារាសាស្ត្រ, ប្រព័ន្ធទឹកស្អាត, បណ្តាញអគ្គិសនី ។ល។; និង ម្យ៉ាងទៀត, ក្នុងការតម្លើងប្រាក់បៀវត្ស, ប្រាក់បំណាច់មុខងារ និង របបសន្តិសុខសង្គម ជូនមន្ត្រីរាជការស៊ីវិល, កងកម្លាំងប្រដាប់អាវុធ, និវត្តជន និង មន្ត្រីបុគ្គលិកគ្រប់ប្រភេទ ទន្ទឹមគ្នានឹងការបង្កើនប្រាក់សោធនប្រចាំខែ សម្រាប់អតីតមន្ត្រីរាជការស៊ីវិល និង អតីតយុទ្ធជន ។ ច្បាស់ណាស់ថា ការសម្រេចបាននូវលទ្ធផលដ៏ប្រសើរខាងលើនេះ មិនអាចកាត់ផ្តាច់ចេញបានឡើយ ពីការចូលរួមចំណែកដ៏សំខាន់ និង មិនអាចខ្វះបាន ពីសំណាក់វិស័យឯកជន ដែលជាក្បាលម៉ាស៊ីនដ៏ចាំបាច់ នៃកំណើនសេដ្ឋកិច្ច និង ជាឆ្អឹងខ្នងដ៏រឹងមាំនៃការអភិវឌ្ឍសង្គមជាតិ ។ ជារួម, វិស័យឯកជន បាន និង កំពុង ចូលរួមបង្កើតការងារ និង មុខរបរ, បង្កើនប្រាក់ចំណូល, កាត់បន្ថយភាពក្រីក្រ, និង ជំរុញការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចកម្ពុជា ប្រកបដោយចីរភាព, បរិយាបន្ន, និង ភាពធន់, ជាពិសេស ក្នុងខណៈដែលស្មារតីស្នេហាជាតិ និង ចលនារួបរួមជាតិ កាន់តែមានសន្ទុះខ្លាំងឡើង, ក្នុងរយៈពេលចុងក្រោយនេះ, ដែលជំរុញដល់ការលើកស្ទួយ និង ការឲ្យតម្លៃខ្ពស់ ដល់ផលិតផលក្នុងស្រុក ។

***ឯកឧត្តម, លោកជំទាវ, ឧកញ៉ា, លោក, លោកស្រី!***

សមិទ្ធផលចម្បងជាច្រើន, ដូចខ្ញុំបានគូសរំលេចខាងលើ, សម្រេចបានមក តាមរយៈការអនុវត្ត នូវគោលនយោបាយ, ផែនការយុទ្ធសាស្ត្រ និង កម្មវិធីកែទម្រង់គន្លឹះនានា ជា-បន្តបន្ទាប់ ប្រកបដោយស្មារតីបុរេសកម្ម និង ការទទួលខុសត្រូវខ្ពស់ ក្នុងការលើកកម្ពស់ភាពប្រកួតប្រជែង និង ការធ្វើពិពិធកម្មសេដ្ឋកិច្ច ។ ជាក់ស្តែង, រាជរដ្ឋាភិបាល បានដាក់ចេញ និង កំពុង ជំរុញអនុវត្ត នូវ **«យុទ្ធសាស្ត្រគៀរគរចំណូល របស់រាជរដ្ឋាភិបាល នីតិកាលទី ៧ នៃរដ្ឋសភា»**, ក្រោម **កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**, ដែលចូលរួមចំណែកកសាងនូវមូលដ្ឋាននៃកំណើនសេដ្ឋកិច្ច ប្រកបដោយចីរភាព និង ការប្រមូលចំណូល ដែលកំពុងឈានទៅរកកម្រិតឧត្តមានុពល តាមរយៈសមិទ្ធផល និង វឌ្ឍនភាពនានានៃការកែទម្រង់ស្ថាប័ន, ការលើកកម្ពស់អភិបាលកិច្ច, ការអភិវឌ្ឍសមត្ថភាពមន្ត្រី, ជាពិសេស ការលើកកម្ពស់វប្បធម៌បង់ពន្ធ និង ការបញ្ជ្រាបការយល់ដឹង ជូនដល់ប្រជា-ពលរដ្ឋ អំពីច្បាប់ និង បទប្បញ្ញត្តិពាក់ព័ន្ធទាំងឡាយ ព្រមទាំង កិច្ចសម្របសម្រួលអន្តរ-ក្រសួង-ស្ថាប័ន ក្នុងការគ្រប់គ្រងការប្រមូលចំណូល ។ **«យុទ្ធសាស្ត្រគៀរគរចំណូល»** ខាងលើ ត្រូវបានរៀបចំឡើង ដោយប្រកាន់ខ្ជាប់នូវ **អភិក្រម ចំនួន ៥** គឺ៖ **(១).** ជានាំនូវការគាំទ្រកំណើនសេដ្ឋកិច្ច ក៏ដូចជា ការបង្កើតបរិយាកាសអំណោយផល ដល់សកម្មភាពសេដ្ឋកិច្ច និង ការជំរុញសកម្មភាពពាណិជ្ជកម្ម; **(២).** មិនបង្កើតប្រភេទពន្ធថ្មី និង មិនដំឡើងអត្រាពន្ធអាករ លើកលែងតែអាករពិសេសលើទំនិញ និង សេវា ដែលប៉ះពាល់ដល់សុខភាព របស់ប្រជាជន, សង្គម និង បរិស្ថាន; **(៣).** ពង្រឹងយន្តការកែលម្អសេវាអ្នកជាប់ពន្ធ តាមរយៈការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាឌីជីថល និង ការពង្រឹងក្រមប្រតិបត្តិមន្ត្រីប្រមូលចំណូល; **(៤).** ជំរុញអនុវត្តវិធានការជាយុទ្ធសាស្ត្រមុតស្រួច ដែលមានចរិតបង្កើតចំណូល, ប៉ុន្តែ មិនបង្កឲ្យមានវិការភាពសេដ្ឋកិច្ច (Economic Distortion) និង ជានាំនូវសមធម៌ និង យុត្តិធម៌ ក្នុងការបង់ពន្ធ; និង **(៥).** ជំរុញការចូលរួមពីវិស័យឯកជន ដើម្បីជានាំឲ្យបាននូវគោលជំហរ និង ការយល់ដឹងរួម, ភាពគ្រប់ជ្រុងជ្រោយនៃវិធានការ និង ភាពជាក់ស្តែងនិយម ដែលផ្សារភ្ជាប់ទៅនឹងចក្ខុវិស័យនៃការប្រែក្លាយប្រព័ន្ធចំណូលរដ្ឋឲ្យមានលក្ខណៈកាន់តែទំនើប, មានប្រសិទ្ធភាព និង ស័ក្តិសិទ្ធិភាពខ្ពស់ ដែលអាចឆ្លើយតបទៅនឹងតម្រូវការនៃការអភិវឌ្ឍ និង ការវិវឌ្ឍយ៉ាងរហ័សនៃរចនាសម្ព័ន្ធសង្គម-សេដ្ឋកិច្ច ។

ផ្អែកតាមអភិក្រមខាងលើ, អគ្គនាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ បាន និង កំពុង ខិតខំបំពេញតួនាទី និង ភារកិច្ច របស់ខ្លួន ប្រកបដោយភាពបុរេសកម្ម និង ស្មារតីទទួលខុសត្រូវខ្ពស់ តាមរយៈការបន្តធ្វើការកែទម្រង់ និង ការអភិវឌ្ឍខ្លួន ជាបន្តបន្ទាប់, ទាំងផ្នែករដ្ឋបាល និង ផ្នែកគោលនយោបាយសារពើពន្ធ, រហូតសម្រេចបាននូវសមិទ្ធផលចម្បងជាច្រើន រួមមាន៖ ១). ការធ្វើទំនើបកម្មមុខងារស្នូល និង មុខងារគាំទ្រមួយចំនួន ដែលជាមូលដ្ឋានដ៏សំខាន់ សម្រាប់ផ្តល់លទ្ធភាព, មធ្យោបាយ និង បរិយាកាស ឲ្យបាន កាន់តែប្រសើរ ជូនដល់អ្នកជាប់ពន្ធ ក្នុងការបំពេញកាតព្វកិច្ចសារពើពន្ធ; ២). ការរៀបចំ ចងក្រង នូវច្បាប់ស្តីពីសារពើពន្ធថ្មី ក្នុងគោលបំណងប្រមូលផ្តុំច្បាប់ និង លិខិតបទដ្ឋាន គតិយុត្ត ស្តីពីពន្ធដារ ជាធរមាន, កែសម្រួល និង បំពេញបន្ថែម នូវបទប្បញ្ញត្តិដែល មានភាពខ្វះចន្លោះ, ដាក់បញ្ចូលនូវគោលការណ៍ទន់ភ្លន់ ដើម្បីអនុវត្តគោលនយោបាយ របស់ រាជរដ្ឋាភិបាល, និង ធានាឲ្យមានសង្គតិភាព ជាមួយច្បាប់ពាក់ព័ន្ធនានា; ៣). ការរៀបចំ នូវសៀវភៅណែនាំបែបបទ និង នីតិវិធីនៃការអនុវត្ត (SOP) ពាក់ព័ន្ធនឹងប្រភេទពន្ធសំខាន់ៗ, ការធ្វើសវនកម្មពន្ធដារ, ការស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌ លើបទប្បញ្ញត្តិស្តីពីពន្ធដារ, ការផ្តល់សេវាអ្នកជាប់ពន្ធ, ការដាក់លិខិតប្រកាសសារពើពន្ធ និង បង់ប្រាក់ពន្ធ, ស្របតាម ស្មារតីនៃវេទិកា រវាងរាជរដ្ឋាភិបាល-ផ្នែកឯកជន លើកទី ១៩; ៤). ការបង្កើតនូវគណៈ-កម្មាធិការជំរុញការដោះស្រាយបញ្ហាវិស័យឯកជន និង យន្តការពាក់ព័ន្ធ ដើម្បីធានានូវ ប្រសិទ្ធភាព និង ស័ក្តិសិទ្ធិភាព នៃការដោះស្រាយនូវរាល់បញ្ហាប្រឈមជាក់ស្តែង របស់វិស័យ ឯកជន ។ល។

មួយវិញទៀត, អគ្គនាយកដ្ឋានពន្ធដារ ក៏បានដាក់ឲ្យអនុវត្តនូវ **ផែនការយុទ្ធសាស្ត្រ ឆ្នាំ ២០២៤-២០២៨** ក្នុងគោលបំណងប្រែក្លាយខ្លួន ទៅជារដ្ឋបាលសារពើពន្ធទំនើប, ឆ្លាតវៃ និង ស្អាតស្អំ ដែលអាចឆ្លើយតបបានសមស្រប ទៅនឹងតម្រូវការរបស់ផ្នែកឯកជន និង ស្របតាមចក្ខុវិស័យរួម នៃ **«យុទ្ធសាស្ត្រកៀរគរចំណូល»** ខាងលើ ផងដែរ ។ បន្ថែមលើនេះទៀត, ដូច ឯកឧត្តម **គង់ វិបុល**, **រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និង ជាប្រតិភូរាជ-រដ្ឋាភិបាល ទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ,** បានគូសបញ្ជាក់ មុននេះ បន្តិច, អគ្គនាយកដ្ឋានពន្ធដារ ក៏ទើបបានរៀបចំ និង អភិវឌ្ឍប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ពន្ធដារកម្ពុជា (Cambodia Tax Administration System), ឬ ហៅកាត់ ជា ភាសាអង់គ្លេស ថា **GDT HomeTax,** ដែលជាថ្នាលបច្ចេកវិទ្យាឌីជីថលដ៏ទំនើប សម្រាប់ការ-

ផ្តល់សេវា ប្រកបដោយគុណភាពខ្ពស់ ជូនអ្នកជាប់ពន្ធ, ហើយដែលខ្ញុំមានកិត្តិយស ក្នុងការប្រកាសដាក់ឲ្យដំណើរការ នាពេលបន្តិចទៀតនេះ ។ ប្រព័ន្ធថ្មីនេះ នឹងអនុញ្ញាតឲ្យអ្នកប្រើប្រាស់ ចូលទៅពិនិត្យ និង បំពេញកាតព្វកិច្ចសារពើពន្ធ តាមទូរស័ព្ទដៃ និង កុំព្យូទ័រ បានយ៉ាងងាយស្រួល, រហ័ស, សាមញ្ញ និង មានសុវត្ថិភាព ។ ខ្ញុំសូមឆ្លៀតយកឱកាសដ៏ប្រពៃនេះ សម្តែងនូវការកោតសរសើរ និង ការវាយតម្លៃខ្ពស់ ចំពោះថ្នាក់ដឹកនាំ និង មន្ត្រីរាជការ គ្រប់លំដាប់ថ្នាក់ នៃអគ្គនាយកដ្ឋានពន្ធដារ, ក្រោមការដឹកនាំដ៏ប៉ិនប្រសប់ របស់ឯកឧត្តម **គង់ វិបុល**, ដែលបានប្រឹងប្រែងយ៉ាងសកម្ម ក្នុងការកៀរគរចំណូលជូនរដ្ឋ តាមរយៈការបន្តខិតខំអភិវឌ្ឍ និង ដាក់ចេញនូវប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានដ៏សម្បូរបែប រហូតសម្រេចបាននូវសមិទ្ធផលជាច្រើន គួរឲ្យកត់សម្គាល់, ដូចខ្ញុំបានគូសរំលេចខាងលើ ។ ច្បាស់ណាស់ថា ក្នុងយុគសម័យឌីជីថលបច្ចុប្បន្ន, កម្ពុជា ត្រូវការជាចាំបាច់ នូវរដ្ឋបាលសារពើពន្ធមួយដែលទំនើប និង ឆ្លាតវៃ ដើម្បីផ្តល់ភាពងាយស្រួល, តម្លាភាព និង គណនេយ្យភាព ជូនអ្នកជាប់ពន្ធ ។ ហេតុដូច្នេះ, ខ្ញុំសូមគាំទ្រ និង លើកទឹកចិត្តអគ្គនាយកដ្ឋានពន្ធដារ ឲ្យបន្តយកចិត្តទុកដាក់ លើការធ្វើបរិវត្តកម្មឌីជីថល សំដៅប្រែក្លាយខ្លួនទៅជា **រដ្ឋបាលសារពើពន្ធទំនើប ឬ ហៅជាភាសាអង់គ្លេស ថា** Tax Administration 3.0 នាពេលខាងមុខ, ស្របតាមចក្ខុវិស័យរួម របស់រាជរដ្ឋាភិបាល, ដូចមានចែងក្នុង **«ក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និង សង្គមឌីជីថលកម្ពុជា ២០២១-២០៣៥»** និង **«គោលនយោបាយរដ្ឋាភិបាលឌីជីថល ២០២២-២០៣៥»**, ដែលជាឯកសារគោលនយោបាយរយៈពេលវែង សម្រាប់ធ្វើជាត្រីវិស័យក្នុងការជំរុញការធ្វើបរិវត្តកម្មឌីជីថល របស់កម្ពុជា ។

## ឯកឧត្តម, លោកជំទាវ, ឧកញ៉ា, លោក, លោកស្រី!

ជាមួយនឹងការសោទរ ចំពោះសមិទ្ធផលការងារជាច្រើនខាងលើ, អគ្គនាយកដ្ឋានពន្ធដារក៏នៅមានកិច្ចការសំខាន់ជាច្រើនទៀត ដែលត្រូវបន្តខិតខំយកចិត្តទុកដាក់សម្រេចឲ្យបានតាមការកំណត់ និង ការចង្អុលបង្ហាញ របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។ ក្នុងន័យនេះ, ជាវិភាគទាន ដើម្បីចាប់យកកាលានុវត្តភាពថ្មីបន្ថែម និង ដើម្បីពង្រឹងប្រសិទ្ធភាព និង ស័ក្តិសិទ្ធិភាព ក្នុងការបំពេញតួនាទី និង ភារកិច្ច ក៏ដូចជា ដើម្បីសម្រេចឲ្យបាន ដោយជោគជ័យ នូវបេសកកម្ម របស់អគ្គនាយកដ្ឋានពន្ធដារ, ខ្ញុំសូមយកឱកាសដ៏វិសេសនេះ ផ្តល់នូវអនុសាសន៍មួយចំនួន ជូនថ្នាក់ដឹកនាំ និង មន្ត្រីរាជការពន្ធដារគ្រប់លំដាប់ថ្នាក់ សម្រាប់

យកទៅអនុវត្ត ជាមួយនឹងស្មារតីទទួលខុសត្រូវខ្ពស់, ដោយមានកិច្ចសហការជិតស្និទ្ធ ពីសំណាក់ក្រសួង-ស្ថាប័នពាក់ព័ន្ធ និង វិស័យឯកជន, ដូចខាងក្រោម៖

ទី១. **ចក្ខុវិស័យ និង លទ្ធផល៖** ខ្ញុំសូមលើកទឹកចិត្តដល់គ្រប់ភាគីពាក់ព័ន្ធទាំងអស់ ដែលបានចូលរួមក្នុង **«វេទិកាពន្ធដារកម្ពុជា»** ពិភាក្សាផ្លាស់ប្តូរយោបល់, ចែក-រំលែកនូវបទពិសោធ និង ចំណេះដឹង, ក៏ដូចជា ផ្តល់នូវអនុសាសន៍ ឲ្យបាន ផុសផុល ជាមួយនឹងភាពជាក់ស្តែងនិយម និង ចក្ខុវិស័យច្បាស់លាស់ សំដៅ រួមចំណែកពង្រឹងប្រសិទ្ធភាព និង ស័ក្តិសិទ្ធិភាព នៃការប្រមូលចំណូលពន្ធជូន រដ្ឋ, ក្នុងស្មារតី **«រួមគ្នាគិត, រួមគ្នាធ្វើ និង រួមគ្នាទទួលខុសត្រូវ»** ដើម្បីសម្រេចបាន នូវលទ្ធផលជាផ្លែផ្កា ដ៏ត្រចះត្រចង់ តាមការរំពឹងទុក នៃការរៀបចំវេទិកានេះ ។

ទី២. **កិច្ចសហប្រតិបត្តិការ និង ភាពជាដៃគូដ៏រឹងមាំ៖** ខ្ញុំសូមជំរុញគ្រប់ភាគីទាំងឡាយ, រួមមាន ក្រសួង-ស្ថាប័នពាក់ព័ន្ធ នៃរាជរដ្ឋាភិបាល, វិស័យឯកជន, ដៃគូអភិវឌ្ឍ និង ស្ថាប័នអន្តរជាតិ, បន្តពង្រឹង និង ពង្រីកកិច្ចសហប្រតិបត្តិការដ៏ជិតស្និទ្ធ និង ភាពជាដៃគូដ៏ស្អិតល្មួត ជាមួយអគ្គនាយកដ្ឋានពន្ធដារ តាមរយៈការពិភាក្សា និង ការផ្លាស់ប្តូរមតិយោបល់, ចំណេះដឹង និង បទពិសោធ ដោយបើកចំហ និង ក្នុងស្មារតីស្ថាបនា ដើម្បីបង្កើនការជឿទុកចិត្តគ្នាទៅវិញទៅមក និង ពង្រឹងការ-គោរពច្បាប់ និង បទប្បញ្ញត្តិគតិយុត្ត ស្តីពីពន្ធដារ, ជាពិសេស ការចូលរួមបំពេញ អនុលោមភាពសារពើពន្ធ ឲ្យបានពេញលេញ ដោយស្ម័គ្រចិត្ត ពីសំណាក់វិស័យ ឯកជន ។

ទី៣. **ការកែទម្រង់, ការធ្វើបរិវត្តកម្មឌីជីថល និង ការអភិវឌ្ឍខ្លួន ឲ្យក្លាយជារដ្ឋបាល សារពើពន្ធដ៏ទំនើប និង ឆ្លាតវៃ (Tax Administration 3.0)៖** ខ្ញុំសូមគាំទ្រ និង លើកទឹកចិត្ត អគ្គនាយកដ្ឋានពន្ធដារ ឲ្យបន្តខិតខំធ្វើបរិវត្តកម្មឌីជីថល និង អភិវឌ្ឍខ្លួន ឲ្យក្លាយជាស្ថាប័នឈានមុខគេមួយ ក្នុងចំណោមអង្គភាពនានា ក្រោមឱវាទក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ តាមរយៈការប្រើប្រាស់នូវបច្ចេក-វិទ្យាទំនើប និង ការធ្វើបរិវត្តកម្មឌីជីថល ស៊ីជម្រៅ និង ទូលំទូលាយ, ដើម្បី លើកកម្ពស់អភិបាលកិច្ច និង ពង្រឹងអនុលោមភាពសារពើពន្ធ សំដៅ, ម្យ៉ាង, ធ្វើឲ្យការបំពេញកាតព្វកិច្ចសារពើពន្ធ របស់វិស័យឯកជន កាន់តែមានភាពងាយ-ស្រួល, ប្រសិទ្ធភាព, ស័ក្តិសិទ្ធិភាព, តម្លាភាព និង គណនេយ្យភាព; និង ម្យ៉ាង ទៀត, បង្កើនចំណូលពន្ធជូនរដ្ឋ ដើម្បីគោលដៅនៃការជំរុញការអភិវឌ្ឍសង្គម-

សេដ្ឋកិច្ចកម្ពុជា ឲ្យមានសម្ទុះកាន់តែខ្លាំងក្លា, ស្របតាមប្រធានបទនៃ «**វេទិកាពន្ធដារកម្ពុជា**» របស់យើង, ក៏ដូចជា ស្របតាមទស្សនវិជ្ជា៖ «**កែទម្រង់-រស់, មិនកែទម្រង់-ស្លាប់**» របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**, អតីត **នាយករដ្ឋមន្ត្រី** និង បច្ចុប្បន្នជា **ប្រធានព្រឹទ្ធសភា** ។ និង

ទី៤. **ការកសាងមូលធនមនុស្ស៖** ខ្ញុំសង្កេតឃើញថា, ក្នុងរយៈកាលកន្លងទៅ, អគ្គនាយកដ្ឋានពន្ធដារ, វិស័យឯកជន និង ក្រសួង-ស្ថាប័នពាក់ព័ន្ធ បានរក្សានូវកិច្ចសហការគ្នាយ៉ាងជិតស្និទ្ធ ក្នុងការបណ្តុះបណ្តាល និង ការពង្រឹងសមត្ថភាពមូលធនមនុស្ស ស្របតាមការវិវត្តយ៉ាងរហ័សនៃសង្គម-សេដ្ឋកិច្ច, និង និន្នាការក្នុងតំបន់ និង លើសកលលោក ។ ក្នុងន័យនេះ, ខ្ញុំសូមលើកទឹកចិត្តដល់គ្រប់ភាគីពាក់ព័ន្ធ បន្តស្មារតីនៃកិច្ចសហការស្អិតល្មួតនេះ និង សូមយកចិត្តទុកដាក់បន្ថែមទៀត ដល់ការបន្តជំរុញការអភិវឌ្ឍមូលធនមនុស្ស ឲ្យកាន់តែមានសមត្ថភាព, សុចរិតភាព, ក្រមសីលធម៌ និង វិជ្ជាជីវៈ ដើម្បីឆ្លើយតបបានសមស្រប ទៅនឹងសំណូមពរការងារ និង តម្រូវការនៃការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចជាតិ, ស្របតាម **យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី ១**, ដែលចាត់ទុក «**មនុស្ស**» ជា **អាទិភាពគន្លឹះ ទី ១** ។

## ឯកឧត្តម, លោកជំទាវ, ឧកញ៉ា, លោក, លោកស្រី!

មុននឹងបញ្ចប់, ជាថ្មីម្តងទៀត, ខ្ញុំសូមសម្តែងនូវអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះថ្នាក់ដឹកនាំ និង មន្ត្រីគ្រប់លំដាប់ថ្នាក់ ព្រមទាំង តំណាង នៃអគ្គនាយកដ្ឋានពន្ធដារ, វិស័យឯកជន, ក្រសួង-ស្ថាប័នពាក់ព័ន្ធ, ដៃគូអភិវឌ្ឍ, ព្រមទាំង អង្គការ និង ស្ថាប័នអន្តរជាតិទាំងឡាយ ដែលបានសហការគ្នាយ៉ាងល្អ ក្នុងការចូលរួមរៀបចំកម្មវិធីដ៏មានសារៈសំខាន់នេះឡើង ដោយរលូន និង បានចំណាយពេលដ៏មានតម្លៃ ចូលរួមដោយផ្ទាល់ នាឱកាសនេះ ជាហេតុធ្វើឲ្យ «**វេទិកាពន្ធដារកម្ពុជា**» ប្រព្រឹត្តទៅយ៉ាងអធិកអធម ។

ខ្ញុំសង្ឃឹមយ៉ាងមុតមាំថា កិច្ចពិភាក្សាក្នុងរយៈពេលពីរថ្ងៃខាងមុខ នឹងដំណើរការទៅប្រកបដោយផ្លែផ្កា តាមការរំពឹងទុក ដោយមានការផ្លាស់ប្តូរមតិយោបល់, ទស្សនៈ, ចំណេះដឹង និង បទពិសោធជាក់ស្តែង យ៉ាងផុសផុល, ក៏ដូចជា ការផ្តល់នូវអនុសាសន៍ផ្នែកគោលនយោបាយ ដែលអាចអនុវត្តបាន ក្នុងបរិបទកម្ពុជា ដើម្បីរួមគ្នាពង្រឹងប្រសិទ្ធ-

ភាព និង ស័ក្តិសិទ្ធិភាពនៃរដ្ឋបាលសារពើពន្ធ, លើកកម្ពស់អនុលោមភាពសារពើពន្ធ និង បង្កើនចំណូលពន្ធជូនរដ្ឋ ក្នុងគោលដៅរួមនៃការជំរុញការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចកម្ពុជា ។

ជាទីបញ្ចប់, ខ្ញុំសូមជូនពរ **ឯកឧត្តម, លោកជំទាវ, ឧកញ៉ា, លោក, លោកស្រី, សមាជិក-សមាជិកា នៃអង្គពិធី** បានសមប្រកបដោយសុខភាពល្អបរិបូរណ៌, សម្រេចបានជោគជ័យក្នុងគ្រប់ភារកិច្ច, ព្រមទាំងទទួលបាននូវវិបុលភាព និង សុភមង្គល ក្នុងក្រុមគ្រួសាររៀងខ្លួន ។

ខ្ញុំមានកិត្តិយស សូមប្រកាស បើកជាផ្លូវការ នូវ «**វេទិកាពន្ធដារកម្ពុជា**» និង សូមប្រកាសដាក់ឲ្យប្រើប្រាស់ នូវ «**ប្រព័ន្ធពន្ធដារកម្ពុជា (GDT HomeTax)**» ចាប់ពីពេលនេះតទៅ៕

*សូមអរគុណ !*